# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ..................ស.ខ.ក.ក.

# សេចក្តីថ្លែងការណ៍

សហគមន៍ខ្មែរកម្ពុជាក្រោម មានការសោកស្តាយ និងក្តីកង្វល់យ៉ាងខ្លាំង ចំពោះការបដិសេធន៍មិនផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនឲ្យប្រជាពលរដ្ឋខ្មែរកំណើតកម្ពុជាក្រោមចំនួន ២២នាក់ ដែលអាជ្ញាធរថៃបានចាប់បញ្ជូនមកអាជ្ញាធរខ្មែរ កាលពីពេលកន្លងទៅថ្មីៗនេះ ។

ការបដិសេធន៍មិនផ្តល់អត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋខ្មែរទាំងនោះ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា៣៣ និងច្បាប់សញ្ជាតិមាត្រា២ មាត្រា៣ និងមាត្រា៤ ។ នេះគឺជាការប្រព្រឹត្ត ផ្ទុយនឹងស្មារតីច្បាប់ និងការអះអាងរបស់ខ្លួនកន្លងមក ដែលបានចាត់ទុកថាប្រជាពលរដ្ឋខ្មែរកំណើតកម្ពុជាក្រោម ជាពលរដ្ឋខ្មែរពេញលក្ខណៈច្បាប់ ។ នេះមិនមែនជាលើកទី១ទេ ដែលរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្នបានប្រកាន់យកជំហរអវិជ្ជមានចំពោះប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមបែបនេះ ។

ក្នុងករណីនេះ បើរាជរដ្ឋាភិបាលខ្មែរចាត់ទុកប្រជាពលរដ្ឋខ្មែរកំណើតកម្ពុជាក្រោមជាពលរដ្ឋខ្មែរ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិ ដូចដែលតំណាងរាជរដ្ឋាភិបាល តែងតែអះអាងជារឿយៗកន្លងមកនោះ សូមរាជរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលក្នុងការ រៀបចំបែបបទផ្លូវច្បាប់សញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋខ្មែរទាំងនោះ ដោយឥតលក្ខខណ្ឌ ។ ដោយសារថា ប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្រោម (វៀតណាមខាងត្បូង) ទោះបីរស់នៅក្រោមការត្រួតត្រារបស់អាណានិគមវៀតណាម រាប់រយឆ្នាំ និងទឹកដីកម្ពុជាក្រោមត្រូវបានអាណានិគមនិយមបារាំង កាត់ផ្ទេរទៅឲ្យអាជ្ញាធរអាណានិគមវៀតណាម ត្រួតត្រាបន្តរហូតមកដល់សព្វថ្ងៃក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរនៅទីនោះ ពុំដែលបោះបង់ចោលអត្តសញ្ញាណ និងសញ្ជាតិជាខ្មែរ ក្បត់ជូនតារបស់ខ្លួនម្តងណាឡើយ សូម្បីតែអាជ្ញាធរវៀតណាមដែលបានផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពរដ្ឋខ្មែរទាំងនោះ ក៏នៅទទួលស្គាល់ថា ពួកគេជាខ្មែរដែរ ។ ជាពិសេសរាជរដ្ឋាភិបាលខ្មែរគ្រប់ជំនាន់ តែងតែបង្កលក្ខណៈល្អប្រសើរ និងលើកទឹកចិត្តគ្រប់បែបយ៉ាង ដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមជានិច្ច លើកលែងតែសម័យពួកកុម្មុយនីស្តផ្តាច់ការដឹកនាំប្រទេសកម្ពុជាតែប៉ុណ្ណោះ ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មេត្តាផ្តល់ឯកសារផ្លូវច្បាប់សញ្ជាតិខ្មែរ ជូនប្រជាពរដ្ឋខ្មែរកំណើតកម្ពុជាក្រោមទាំងអស់ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិ ដោយឥតលក្ខខណ្ឌ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០*

**ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៣៣ ០០៣

E-mail: senthach2000@yahoo.com: Website: http//khmerkromngo.org